family planning nsw
Reproductive & Sexual Health

# ឯកសារព័ត៌មាន

# ការរំលូតកូនដោយការវះកាត់ ឬការរំលូតកូនដោយការប្រើថ្នាំ - តើខុសគ្នាត្រង់ចំណុចណា ?

| | ការរំលូតកូនដោយការវះកាត់ | ការរំលូតកូនដោយការប្រើថ្នាំ |
|---|---|---|
| **ការធ្វើតេស្តដែលតម្រូវឱ្យមាន** | • ការធ្វើតេស្តឈាម - មុន<br>• ឆ្លុះអេកូត្រីមាសទីមួយ | • ការធ្វើតេស្តឈាម – មុន និងក្រោយ<br>• ឆ្លុះអេកូត្រីមាសទីមួយ |
| **ពេលវេលា** | • ជាធម្មតាត្រូវបានធ្វើឡើងបន្ទាប់ពីគភ៌មានអាយុ 6 សប្តាហ៍<br>• កាន់តែថ្លៃចំពោះគភ៌ដែលមានអាយុលើសពី 12 សប្តាហ៍ | • ត្រូវធ្វើឡើងមុនសប្តាហ៍ទី 9 នៃការមានផ្ទៃពោះ<br>• ជាធម្មតាត្រូវបានធ្វើឡើងបន្ទាប់ពីគភ៌មានអាយុ 6 សប្តាហ៍ |
| **ដំណើរការ** | • តម្រូវឱ្យមានការប្រើថ្នាំស្ពឹកកម្រិតស្រាល<br>• នីតិវិធីវះកាត់នៅគ្លីនិកវះកាត់ពេលថ្ងៃ<br>• នីតិវិធីត្រូវចំណាយពេលប្រហែល 10 នាទី<br>• រយៈពេលនៃការធូរស្បើយឡើងវិញគឺរហូតដល់ 4 ម៉ោង នៅគ្លីនិកវះកាត់ពេលថ្ងៃ<br>• ជួនកាលមានធ្លាក់ឈាមតិចៗរហូតដល់ 2 សប្តាហ៍ ឬមិនមានហូរឈាម<br>• មានផ្តល់ថ្នាំផ្សះ<br>• មានការណាត់ជួបតាមដានតែក្នុងករណីដែលមានផលវិបាក ឬមានកង្វល់ប៉ុណ្ណោះ | • លេបថ្នាំនៅផ្ទះរបស់អ្នកផ្ទាល់ ឬនៅកន្លែងដែលមានសុវត្ថិភាពផ្សេងទៀត<br>• ការរមួលស្បូន និងធ្លាក់ឈាមច្រើនក្នុងរយៈពេលពីរបីម៉ោងដំបូង<br>• ការធ្លាក់ឈាមតិចៗ ជាធម្មតាមានរយៈពេលប្រហែល 2 សប្តាហ៍ ប៉ុន្តែអាចបន្តរហូតដល់ 6 សប្តាហ៍<br>• ណែនាំឱ្យប្រើគ្រាប់ថ្នាំបំបាត់ការឈឺចាប់ និងថ្នាំមិនឱ្យក្អួត<br>• តម្រូវឱ្យមានការណាត់ជួបតាមដាន ដើម្បីប្រាកដថាការរំលូតកូនបានបញ្ចប់ |
| **ការគាំទ្រ និងការធូរស្បើយឡើងវិញ** | • អ្នកនឹងត្រូវការមនុស្សពេញវ័យដែលមានទំនួលខុសត្រូវ ដើម្បីនាំអ្នកពីគ្លីនិកវះកាត់ពេលថ្ងៃទៅផ្ទះ<br>• អ្នកមិនអាចបើកបរបន្ទាប់ពីការអនុវត្តនិតិវិធីបានទេ | • អ្នកនឹងត្រូវមានមនុស្សពេញវ័យដែលមានទំនួលខុសត្រូវមកជាមួយអ្នកដើម្បីជួយក្នុងរយៈពេល 24 ម៉ោងដំបូងបន្ទាប់ពីការប្រើថ្នាំ |
| **ផលរំខាន** | • អាចមានអារម្មណ៍អស់កម្លាំងដោយសារថ្នាំស្ពឹក<br>• អាចមានធ្លាក់ឈាម និងរមួលស្បូនតិចតួច – ជាធម្មតាតិចជាង 2 សប្តាហ៍ | • គេរំពឹងថានឹងមានការរមួលស្បូន និងធ្លាក់ឈាម<br>• អាចនឹងមានអាការៈក្តៅខ្លួន ញាក់ ក្អួត ចង្អោរផងដែរ |
| **ផលវិបាក / ហានិភ័យ** | • របួសភ្នាសក្នុងស្បូន ឬមាត់ស្បូន<br>• ការឆ្លងមេរោគ<br>• ការធ្លុះស្បូន (រន្ធតូច)<br>• ប្រតិកម្មនឹងថ្នាំស្ពឹក | • ការធ្លាក់ឈាមច្រើន<br>• ការឆ្លងមេរោគ<br>• ការរំលូតកូនមិនពេញលេញ<br>• ការបន្តមានផ្ទៃពោះ |
| | • ផលវិបាកសម្រាប់ការរំលូតកូនដោយការវះកាត់ និងដោយការប្រើថ្នាំគឺកម្រមានណាស់ | |
| **អាចរកបាននៅ FPNSW** | • អាចធ្វើបានសម្រាប់គភ៌ដែលមានអាយុរហូតដល់ 12 សប្តាហ៍ + 6 ថ្ងៃនៅ Chatswood<br>• តម្រូវឱ្យមានការណាត់ជួប 2 ដង – ការវាយតម្លៃ និងនីតិវិធី | • អាចធ្វើបានសម្រាប់គភ៌ដែលមានអាយុរហូតដល់ 9 សប្តាហ៍នៅគ្រប់គ្លីនិក FPNSW ទាំងអស់<br>• តម្រូវឱ្យមានការណាត់ជួប 3 ដង – ការវាយតម្លៃ ការចេញវេជ្ជបញ្ជា និងការតាមដាន |

## សម្រាប់ព័ត៌មានបន្ថែម

**បណ្ដាញ Family Planning NSW Talkline** – www.fpnsw.org.au/talkline ឬ 1300 658 886

**សេវាកម្មបញ្ជូនបន្តថ្នាក់ជាតិ** (សម្រាប់មនុស្សថ្លង់) – 13 36 77

**សេវាកម្មបកប្រែ TIS National's interpreting service** – 131 450

**ទៅកាន់គ្លីនិក Family Planning NSW ដែលនៅជិតអ្នកបំផុត** – www.fpnsw.org.au/clinics

**ឯកសារព័ត៌មានអតិថិជនរបស់ Family Planning NSW** – https://www.fpnsw.org.au/factsheets/individuals/cervical-screening/hpv-vaccination

**ធនធានអតិថិជនរបស់ Family Planning NSW** – https://www.fpnsw.org.au/changes



Family Planning NSW គឺជាអង្គការមិនរកប្រាក់ចំណេញដែលទទួលមូលនិធិពីក្រសួងសុខាភិបាលរដ្ឋ NSW
ព័ត៌មាននៅក្នុងឯកសារព័ត៌មាននេះត្រូវបានផ្ដល់ជូនក្នុងគោលបំណងអប់រំតែប៉ុណ្ណោះ។ Family Planning NSW (FPNSW) បានយកចិត្តទុកដាក់គ្រប់បែបយ៉ាងដើម្បីធានាថាព័ត៌មាននេះគឺត្រឹមត្រូវ និង ទាន់សម័យនៅពេលបោះពុម្ពផ្សាយ។ វាមិនមានបំណងផ្ដល់ដំបូន្មានផ្នែកវេជ្ជសាស្ត្រជាក់លាក់ ឬជំនួសដំបូន្មានជាលក្ខណៈបុគ្គលពីអ្នកជំនាញថែទាំសុខភាពនោះទេ។ រក្សាសិទ្ធិ @ FPNSW 2018។
Uមិនអនុញ្ញាតឱ្យចម្លងធ្វើឯកសារព័ត៌មាននេះដោយគ្មានការអនុញ្ញាតឡើយ។ ពិនិត្យឡើងវិញ៖ ខែតុលា ឆ្នាំ 2020